ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ០១ អយក ៧៣ ន

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹងការអនុវត្តកាតព្វកិច្ចរបស់បុគ្គលិកអប់រំ

កន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានសង្កេតឃើញថា បុគ្គលិកអប់រំគ្រប់ឋានានុក្រម បានអនុវត្តនូវកាតព្វកិច្ចដែលមានកំណត់នៅក្នុងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យអប់រំយ៉ាងខ្ជាប់ខ្ជួន និងគួរជាទីមោទនៈ។ ទន្ទឹមនឹងនេះ នៅមានមជ្ឈដ្ឋានខាងក្រៅមួយចំនួនបានបង្កនូវការញុះញង់ដល់បុគ្គលិកអប់រំ ដែលបណ្តាលឱ្យមានការរំខានដល់ការអនុវត្តកាតព្វកិច្ចដែលមានកំណត់នៅក្នុងច្បាប់ស្តីពីការអប់រំ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងលិខិតបទដ្ឋានគតិយុត្តរបស់វិស័យអប់រំដែលនៅជាធរមាន។

ដើម្បីពង្រឹងការអនុវត្តកាតព្វកិច្ចដែលមានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ឱ្យបានកាន់តែល្អប្រសើរថែមទៀត ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោម៖

១. បុគ្គលិកអប់រំទាំងអស់ត្រូវប្រើសិទ្ធិ សេរីភាពរបស់ខ្លួនដោយមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃ ដូចបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៣១ ថា "**ការប្រើសិទ្ធិ សេរីភាពរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ**"។ ម្យ៉ាងទៀត នៅក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រង់មាត្រា ២ បានកំណត់ថា "**ច្បាប់នេះមានគោលបំណង ធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនត្រូវឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព និងកិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គមជាតិ ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ**"។ ដូច្នេះ បុគ្គលិកអប់រំ ត្រូវធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការអប់រំរបស់អ្នកសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. បុគ្គលិកអប់រំទាំងអស់ ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដូចបានកំណត់នៅក្នុងច្បាប់ស្តីពីការអប់រំ ត្រង់មាត្រា ៣៧ ថា បុគ្គលិកអប់រំត្រូវ៖ "**គោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន បំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ជាធរមាន អនុវត្តនិងអភិវឌ្ឍការងាររបស់ខ្លួនដោយយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់**"។ ដូច្នេះ បុគ្គលិកអប់រំទាំងអស់ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ជាពិសេសត្រង់មាត្រា ១៧ មាត្រា ១៩ និងមាត្រា ២៤ ដែលមានខ្លឹមសារដូចខាងក្រោម៖

- មាត្រា ១៧ បានកំណត់ថា "**គ្រូបង្រៀនមានករណីយកិច្ចបង្រៀន ដោយមិនត្រូវដាក់សម្ពាធយកជាប្រយោជន៍លើអ្នកសិក្សាឡើយ**"។


អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៥៦ / ៤២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

- មាត្រា ១៩ បានកំណត់ថា "គ្រូបង្រៀនមិនត្រូវប្រព្រឹត្តសកម្មភាពខុសច្បាប់ ដែលនាំឱ្យមានការប៉ះពាល់ដល់ការបង្រៀននិងការរៀន និងការប្រឡងរបស់អ្នកសិក្សាឡើយ"។
- មាត្រា ២៤ បានកំណត់ថា "គ្រូបង្រៀនមិនត្រូវធ្វើឱ្យប៉ះពាល់ ឬ ខូចខាតដល់គុណភាពអប់រំក្នុងការបំពេញការងារ ទោះបីតាមរូបភាពណាក៏ដោយ"។

៣. បុគ្គលិកអប់រំត្រូវបំពេញកាតព្វកិច្ចក្នុងពេលបំពេញការងាររួមមាន កាតព្វកិច្ចរ៉ាប់រងសេវារបស់ខ្លួន កាតព្វកិច្ចគោរពម៉ោងធ្វើការ កាតព្វកិច្ចបំពេញតួនាទីរបស់ខ្លួន កាតព្វកិច្ចគោរពឋានានុក្រម កាតព្វកិច្ចប្រកាន់យកភាពថ្លៃថ្នូរនិងមានកិត្តិយស កាតព្វកិច្ចលក្ខការណ៍គោរពការសម្ងាត់វិជ្ជាជីវៈ កាតព្វកិច្ចអព្យាក្រឹតក្នុងការងារ កាតព្វកិច្ចភក្តីភាព និងគិតគូរផលប្រយោជន៍ទូទៅ ដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ពិសេសមាត្រា ៣៣ មាត្រា ៣៤ និងមាត្រា ៣៥ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- មាត្រា ៣៣ "អ្នករាជការរាល់រូប ត្រូវតែគោរពអនុវត្តច្បាប់ និងបទបញ្ជា ហើយនិងការណែនាំថ្នាក់លើរបស់ខ្លួន។ អ្នករាជការ ត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែលធ្វើឱ្យប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់ខ្លួន"។
- មាត្រា ៣៤ "អ្នករាជការទាំងឡាយ មិនអាចឈប់ធ្វើការដោយគ្មានបានទទួលការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន ឬដោយគ្មានមូលហេតុត្រឹមត្រូវ។ ការឈប់ធ្វើការ ឬការខានទៅធ្វើការដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវ អាចបង្ខំឱ្យអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស"។
- មាត្រា ៣៥ "ត្រូវហាមឃាត់ជាដាច់ខាត ដល់អ្នករាជការនូវប្រការខាងក្រោម៖ ១. យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត។ ២. យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ដើម្បីសំឡុត គំរាមកំហែងបំពានសិទ្ធិរបស់ពលរដ្ឋ។ ៣. ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ "។
- មាត្រា ៣៧ "មន្ត្រីរាជការត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និងហាមដាច់ខាតនូវការប្រើមុខងាររបស់ខ្លួន និងសម្ភាររបស់រដ្ឋដើម្បីបម្រើសកម្មភាពនយោបាយ"។

៤. ក្នុងករណីបុគ្គលិកអប់រំ បំពេញកាតព្វកិច្ចដោយខ្ជីខ្ជា ឬបំពេញមិនបានពេញលេញ ឬមិនបានបំពេញកាតព្វកិច្ចទាំងស្រុង ដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីការអប់រំ និងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ត្រូវទទួលទណ្ឌកម្មខាងវិន័យតាមមាត្រា ៤០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដូចខាងក្រោម៖

ក. ទណ្ឌកម្មខាងវិន័យថ្នាក់ទី១៖

- ស្តីបន្ទោស
- ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់។

ខ. ទណ្ឌកម្មខាងវិន័យថ្នាក់ទី២៖

- ស្ដីបន្ទោសជាទម្ងន់ បណ្ដាលឱ្យលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ បើសិនជាមានចុះឈ្មោះហើយ ឬធ្វើឱ្យយឺតក្នុងការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់ក្នុងថេរវេលាមួយមានកំណត់ តែមិនត្រូវឱ្យលើសពី២ឆ្នាំ ក្នុងការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់តាមវេនជ្រើសរើស ឬតាមវេនអតីតភាព
- ដាក់ឱ្យនៅទំនេរគ្មានបៀវត្ស មិនឱ្យលើសពីមួយឆ្នាំ
- បន្ថយឋានន្តរស័ក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់
- ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ
- បណ្ដេញចេញពីមុខតំណែងរាជការ។

៥. ចំពោះបុគ្គលិកអប់រំដែលញុះញង់ ឱ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈត្រូវប្រឈមនឹងការទទួលទណ្ឌកម្មតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៥០៥ ដែលបានកំណត់ថា "**ការញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយថ្ងៃទៅមួយខែ និងពិន័យជាប្រាក់ពី ១ ០០០រៀល ទៅ ១ ០០ ០០០រៀល**"។

៦. ក្នុងករណីបុគ្គលិកអប់រំធ្វើសកម្មភាពឱ្យប៉ះពាល់ដល់អព្យាក្រឹតភាពរបស់ស្ថាប័នអប់រំ និងគ្រឹះស្ថានសិក្សា ត្រូវទទួលទណ្ឌកម្ម តាមមាត្រា ៥២ នៃច្បាប់ស្តីពីការអប់រំដែលកំណត់ថា «**គ្រប់សកម្មភាពនយោបាយ ឬការឃោសនានយោបាយ ឱ្យគណបក្សនយោបាយណាមួយនៅក្នុងស្ថាប័នអប់រំ ឬគ្រឹះស្ថានសិក្សាដែលផ្ទុយនឹងមាត្រា ៣៤ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១ ០០០ ០០០រៀល ទៅ ៥ ០០០ ០០០រៀល** »។

ទទួលបានសេចក្តីណែនាំនេះ ប្រធានអង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ សាកលវិទ្យាធិការ នាយក នាយិកាគ្រឹះស្ថានសិក្សា និងអង្គភាពពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់បុគ្គលិកអប់រំគ្រប់ឋានានុក្រមឱ្យអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីស្តីទី**

**ពិត ចំណាន**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងយុត្តិធម៌

*« ដើម្បីជូនជ្រាប »*

- គ្រប់សាលារាជធានី ខេត្ត *« ដើម្បីសហការអនុវត្ត »*
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡា *« ដើម្បីអនុវត្ត »*
- ឯកសារ កាលប្បវត្តិ នា. នីតិកម្ម